ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភា រដ្ឋប្បវេណី
ឈ្មោះរឿងរដ្ឋប្បវេណី
លេខ : ២២៩
ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៨

សាលដីកា

លេខ : ២៣
ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :-

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន
២- លោក ខែប៉ន ស៊ិន ជាចៅក្រម
៣- លោក ទេវ៉ុល ធួន ជាចៅក្រម
៤- លោក ស៊ិន ឌឹម ជាចៅក្រម
៥- លោក ជីវ កេង ជាចៅក្រម

ក្រឡាបញ្ជី

កញ្ញា សេន សុខា

តំណាងអយ្យការ

លោក ខែប៉ន ហាវឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសារទុក្ខពីសាលដីកាលេខ ២៥៨ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៨ នៃឈ្មោះរឿងរដ្ឋប្បវេណីលេខ ២៥៦ ចុះថ្ងៃទី២៨ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសារទុក្ខអ្នកស្រី មាស សំអឿន អាយុ ៤៦ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ថ្នាំពេទ្យ ទីលំនៅភូមិផ្សារឆ្នាំង ស្រុក កំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។

និង ចុងចម្លើយបណ្តឹងសារទុក្ខលោក សូ រិន អាយុ ៤៨ ឆ្នាំ ជាតិ ខ្មែរ មុខរបរ អនុប្រធានទី ១ ខេត្តកំពង់ឆ្នាំង មានទីលំនៅភូមិ ទួលក្រឡាញ់ សង្កាត់ ទី ២ ទីរួមខេត្ត កំពង់ឆ្នាំង ។

កម្មវត្ថុបណ្តឹង : ប្តឹងពីបទរំលោភកម្មសិទ្ធិផ្ទះ និង សុំបដិសេធសេចក្តីសម្រេចរបស់ខេត្ត ។

បានឃើញបណ្តឹងសារទុក្ខលេខ ២១៤ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ១៩៩៨ របស់អ្នកស្រី មាស សំអឿន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២៥៨ ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

--- ២ --

បាន ឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២២៩ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៨ របស់ តុលាការកំពូល ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ០៥.៦.៩២ របស់លោក លូ រិន ជាដើមចោទថា ដំបូងឡើយ ឈ្មោះ លាស់ ស៊ុំ ត្រូវជាប្ដីរបស់អ្នកស្រី មាស សំអឿន ជាចុងចម្លើយ បានមកពឹងអោយខ្លួន ជួយរកជួលផ្ទះមួយល្វែង ដើម្បីបន្តមុខរបរលក់ថ្នាំពេទ្យ និង ព្យាបាលជំងឺត្រង់ផ្លូវផ្សារក្រោមទីរួមខេត្ត ខេត្តកំពង់ឆ្នាំង ។ ហើយខ្លួន ក៏បានអោយទៅជួលផ្ទះរបស់មន្ទីរបក្សខេត្ត ។ រីឯថ្ងៃឈ្នួល លាស់ ស៊ុំ និង ភរិយា ជាអ្នកពិភាក្សាផ្ទាល់ជាមួយ និង លោក ប៉ែន អឿន អតីតប្រធានមន្ទីរ បក្សខេត្ត ក្រោយមកខ្លួន ក៏បានដាក់ពាក្យសុំផ្ទះ ដែលលោក លាស់ ស៊ុំ និង អ្នកស្រី មាស សំអឿន ជួលនេះទៅគណៈកម្មាធិការប្រជាជនខេត្ត ដើម្បីធ្វើសិទ្ធិរបស់ខ្លួន ហើយខេត្ត ក៏បានយល់ព្រមប្រគល់ផ្ទះនោះអោយមកខ្លួន រួចលោក ប៉ែន អឿន ប្រធានមន្ទីរ បក្សខេត្ត ក៏បានផ្ទេរថ្ងៃឈ្នួលផ្ទះអោយមកខ្លួន ហើយអ្នកស្រី មាស សំអឿន ក៏បានបង់ថ្ងៃឈ្នួលផ្ទះមកអោយខ្លួន ជាបន្តបន្ទាប់វិញ ។ លុះដល់ចុងខែ ធ្នូ ឆ្នាំ ១៩៩១ អ្នកស្រី មាស សំអឿន បានពឹងអោយខ្លួនជួយរកផ្ទះមួយល្វែងទៀតដើម្បីបន្តមុខរបរ ។ ពេលនោះខ្លួន បានដឹងថា ផ្ទះកាត់ដេររបស់សមាគមនារី នៅទំនេរគេចង់បញ្ចាញ ហើយខ្លួនក៏ប្រាប់ទៅអ្នកស្រី មាស សំអឿន ប៉ុន្តែអ្នកស្រី មាស សំអឿន ពុំបានទៅពិភាក្សាជាមួយសមាគមនារីទេ ហើយស្រាប់តែនៅដើមខែ កុម្ភៈ ១៩៩២ អ្នកស្រី មាស សំអឿន បានមកនិយាយថាជូនលាភសំណាងមកខ្លួន ចំនួន ៣តម្លឹងមាស ហើយគាត់សុំដកផ្ទះនេះតែម្ដង តែខ្លួនមិនយល់ព្រមតាម ។ ដូច្នេះខ្លួន ប្ដឹងទាមទារផ្ទះកើតហេតុនេះមកធ្វើជាកម្មសិទ្ធិតាមសេចក្ដីសំរេចរបស់ខេត្ត ដែលយល់ព្រមប្រគល់អោយខ្លួន រួចហើយ ។

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ២៥.០១.៩៧ របស់នាង មាស សំអឿន និង លោកលាស់ ស៊ុំ ថា ខ្លួន និង គ្រួសារ បានមករស់នៅលើផ្ទះកើតហេតុតាំងពីឆ្នាំ ១៩៩១ ហើយត្រូវបានរដ្ឋអំណាចភូមិ ឃុំ ទទួលស្គាល់ត្រឹមត្រូវ ប៉ុន្តែបែរជាមានសេចក្ដីសំរេចលេខ ៨១ សសរ .គខ ចុះថ្ងៃទី ២៥.០១.៩២ សំរេចប្រគល់ផ្ទះដែលខ្លួនកំពុងរស់នៅ អោយទៅអ្នកផ្សេងទៅវិញ ។ ខ្លួនរស់នៅអស់រយៈពេល ៧ ឆ្នាំមកហើយបើគិតមកដល់ពេលនេះ ។ ខ្លួនសូមអោយតុលាការបដិសេធសេចក្ដីសំរេចនេះពីព្រោះថាសេចក្ដីសំរេចរបស់ឯកឧត្ដម ដោក ណារិន នេះមិនត្រឹមត្រូវតាមច្បាប់ទេ ។

បាន ឃើញដីកាសំរេចកិច្ចការប្រញាប់លេខ ០៨ តរ.៩៣ ចុះថ្ងៃទី ០១.០២.១៩៩៣ របស់ តុលាការខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១ - ទទួលពាក្យបណ្ដឹងជាកិច្ចការប្រញាប់ ចុះថ្ងៃទី ២១.១២.៩២ របស់នាង សៀង គីមឡេង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - បង្គាប់អោយឈ្មោះនាង មាស សំអឿន និង ឈ្មោះ លាស់ ស៊ុំ " ប្ដី ប្រពន្ធ " ព្រមទាំងគ្រួសារ យកអីវ៉ាន់ទ្រព្យសម្បត្តិជាចលនៈ និង អចលនៈ និង សំភារៈពាក់ព័ន្ធរបស់ខ្លួនទាំងប៉ុន្មាន ចេញផុតពីលំនៅដ្ឋាន ហើយហាមលក់ បញ្ចាំ ទៅតតីយជនដទៃឡើយ ផ្ទះល្វែងលើក្រោមចំណុចផ្សារក្រោម ជាប់ការិយាល័យជលផលខេត្តកំពង់ឆ្នាំង ចាប់ពីថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

៣ - ប្រគល់ផ្ទះល្វែងលើក្រោមដែលមានទំហំទទឹង ៥,៥ម បណ្ដោយ ២៦,២០ម ទៅ

ឲ្យ .

គណៈកម្មាធិការប្រជាជនខេត្តកំពង់ឆ្នាំង គ្រប់គ្រងបណ្ដោះអាសន្នរង់ចាំសំរេចរឿងអង្គសេចក្ដី ។

៤ - បង្គាប់អោយលោក ស្នងការនគរបាលខេត្តកំពង់ឆ្នាំង តាមដានអនុវត្តតាមអំណាចដីកានេះដោយបិទក្រដាសពាសលើទ្វា បង្អួច និង ចាក់សោរអោយមានប្រសិទ្ធិភាពខ្ពស់បណ្ដោះអាសន្ន ចាំដល់សំរេចរឿងអង្គសេចក្ដី ។

សេចក្ដីសំរេចនេះមានអនុភាពអនុវត្តភ្លាម ៗ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៦ ចុះថ្ងៃទី ០៦.០៤.៨៤ របស់តុលាការខេត្តកំពង់ឆ្នាំង សំរេចចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :-

១ - សំរេចទទួលស្គាល់ពាក្យបណ្ដឹងរបស់ដើមចោទ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៨២ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - សំរេចអោយឈ្មោះ ខាល សំអឿន ព្រមទាំងញាតិលោហិតគ្រប់ជាន់ថ្នាក់ ប្រគល់ផ្ទះថ្មពីរជាន់កន្លះជាប់ការិយាល័យជលផលខេត្ត ទៅអោយអ្នកស្រី សៀង គឹមទៀង កាន់កាប់ប្រើប្រាស់ ចាត់ចែងជាសម្បត្តិផ្ទាល់ខ្លួន ចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៣ - សំរេចអោយឈ្មោះអ្នកស្រី មាស សំអឿន ព្រមទាំងញាតិលោហិតគ្រប់ជាន់ថ្នាក់ រុះរើសំភារៈផ្ទាល់ខ្លួន យកចុះចេញផុតពីផ្ទះថ្មពីរជាន់កន្លះ និង ដីភូមិទាំងមូលនេះរយៈពេល ៣០ថ្ងៃ ចាប់តាំងពីថ្ងៃប្រកាសសាលក្រម ទោះបីជាចុងចម្លើយ ប្ដឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ក៏ដោយ ។

៤ - សំរេចអោយអ្នកស្រី មាស សំអឿន បង់ប្រាក់ថ្លៃឈ្នួលផ្ទះមួយខែពុចំនួន ៣០.០០០ រៀល " បីម៉ឺនរៀល " ដែលមិនទាន់បង់ដោយគិតតាំងពីខែ ០៦ ឆ្នាំ ១៩៨២ រហូតមកដល់ថ្ងៃអនុវត្តសាលក្រម ។

- សំរេចអោយអ្នកស្រី មាស សំអឿន ចុងចម្លើយ សងសំណងជំងឺចិត្តជាប្រាក់រៀល ចំនួន ១៥០លានរៀល " ១៥០.០០០.០០០រៀល " ទៅអោយអ្នកស្រី សៀង គឹមទៀង សុំលើសពីនេះបដិសេធចោល ។

- សំរេចអោយចុងចម្លើយសងប្រាក់ប្រដាប់ក្ដី គឺ ពន្ធចុះបញ្ជីក្ដី និង ពន្ធប្ដឹង ១៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ចំនួន ២០០រៀល រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០រៀល បូករួម៧០០០ រៀល ប្រាក់នេះបានកាត់យកពីប្រាក់ដើមចោទ បង់ទុករួចហើយ ។ បើប្ដឹងឧទ្ធរណ៍ បង្គាប់អោយចុងចម្លើយ សងប្រាក់ប្រដាប់ក្ដី ៧០០០រៀលទៅដើមចោទ និង អោយបង់ពន្ធសមាមាត្រ ១ភាគរយលើប្រាក់ដែលត្រូវលោក សូ រិន ។

៦៦.០០០.០០០ គុណ ១ / ១០០ : ៦៦.០០០០៛០០ បន្ថែមទៀតដែលត្រូវដាក់ចូលជា ថវិការដ្ឋ

៦៦០.០០០ គុណ ៨០ / ១០០ : ៥២៨.០០០៛០០ និង ជារង្វាន់ក្រឡាបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា

៦៦០.០០០ គុណ ២០ / ១០០ : ១៣២.០០០៛០០

តាមមាត្រា ៣៤ ច្បាប់ស្ដីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨.១០.៨៨ ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ



៣៧ ,

បើភាគីណាមួយមិនសុខចិត្តអាចប្តឹងទាស់ ក្នុងកំណត់ ១៥ ថ្ងៃគិតពីថ្ងៃទទួលដំណឹង និង ប្តឹងឧទ្ធរណ៍ ២ខែ គិតពីថ្ងៃផុតបណ្តឹងទាស់ ។

បាន ឃើញសាលក្រមរដ្ឋប្បវេណីលេខ ២៥ ចុះថ្ងៃទី ១៣.៦.១៩៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង សម្រេចកំបាំងមុខចុងចម្លើយជាលើកទី ២ ចាត់ទុកដូចជាចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :-

- ចំពោះមុខអ្នកស្រី សៀង គីមឡេង កំបាំងមុខអ្នកស្រី មាស សំអឿន ។

- សម្រេចតម្កល់សាលក្រមលើកទី ១ លេខ ១៦ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៩៤ ទុកជាបានការពេញទាំងមូល ។

សាលក្រមជំនុំជំរះកំបាំងមុខចុងចម្លើយ ជាលើកទី ២ ចាត់ទុកដូចជាចំពោះមុខគូក្តី ។ គូក្តីមានសិទ្ធិប្តឹងឧទ្ធរណ៍ រយះពេល ២ខែក្នុងកំណត់ច្បាប់ ។

បាន ឃើញបណ្តឹងទាស់ ចុះថ្ងៃទី ០៣.៨.១៩៩៤ របស់អ្នកស្រី មាស សំអឿនប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ២៥ ចុះថ្ងៃទី ១៣.៦.១៩៩៤ លើសេចក្តីសម្រេចទាំងមូល ។

បាន ឃើញសាលក្រមរដ្ឋប្បវេណីលេខ ៧៩ ចុះថ្ងៃទី ១៨.០៩.៩៧ របស់តុលាការខេត្តកំពង់ឆ្នាំង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :-

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទ ចុះថ្ងៃទី ២៦.០១.៩៧ ទុកជាមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធ សេចក្តីសម្រេចស្តីពីការប្រគល់ដី និង ផ្ទះមួយល្វែងជូនលោក លូ ទិន លេខ ៨១ សរ.ស.រ.គខ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩២ នេះទុកជាមោឃះ ។

៣- ទីបង្គាប់ប្រាក់ប្រដាប់ក្តី គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង ១៨០០រៀល វង្វាន់ក្រឡាបញ្ជី កានវិបប្រាក់ ២០០រៀល វង្វាន់អ្នកប្រគល់ដីការកោះ ៥០០០រៀល បូកសរុប ៧០០០រៀល ប្រាក់នេះគឺ ប្រាក់ដែលដើមចោទ បានបង់រួចហើយ ។

- សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខដើមចោទ បើកផ្លូវអោយដើមចោទ និង តំណាងអភិបាលខេត្តកំពង់ឆ្នាំង ប្តឹងឧទ្ធរណ៍រយះពេល ២ខែតាមកំណត់ច្បាប់ ។

បាន ឃើញបណ្តឹងឧទ្ធរណ៍លេខ ១៦ ចុះថ្ងៃទី ២៥.៩.៩៧ របស់លោក ម៉ែន គឿន តំណាងអោយអភិបាលខេត្តកំពង់ឆ្នាំង ប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ ៧៩ ចុះថ្ងៃទី ១៨.០៩.៩៧ លើសេចក្តីសម្រេចទាំងមូល ។

បាន ឃើញសាលដីការបៀបលេខ ៣៨ ចុះថ្ងៃទី ១៧.៥.៩៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :-

១- សួរទៅតុលាការខេត្តកំពង់ឆ្នាំង អំពីសាលក្រមលេខ ១៦ ចុះថ្ងៃទី០១.៤.៩៤ សាលក្រមលេខ ២៥ ចុះថ្ងៃទី ២៥.៦.១៩៩៤ ហើយអោយចម្លងសាលក្រមទាំងពីរនេះព្រមទាំងកំណត់ហេតុជំនុំជំរះផង ។ សួរអំពីសេចក្តីសម្រេច តម្កល់សំណុំរឿងមិនចាត់ការលេខ ១១៥.៩៥ ចុះថ្ងៃទី០៨.៥.៩៥ មានប្តឹងឧទ្ធរណ៍ ដែរទេ ។

២ - អោយអាជ្ញាធរចូលផ្ទាល់បញ្ជាក់អំពីនាង មាស សំអឿន ដែលបានចូលមកស្នាក់នៅលើទីតាំងទំនាស់ តើនាងបានចូលមកនៅក្នុងឆ្នាំណា ? ហេតុដូចម្តេចបានជានាងនេះចូលមកស្នាក់នៅបាន ផ្ទះនេះមុនដែលនាងមាស សំអឿន បានចូលមកស្នាក់នៅ តើមានជនណាមួយ បានស្នាក់នៅរួចទៅហើយ ឬក៏នៅទំនេរ ? ក្នុងការទំនាក់ទំនងរវាងលោក សូ រិន និង នាង មាស សំអឿន មុនដែលមានទាស់ទែងគ្នា តើបញ្ហាផ្ទះទំនាស់នេះនៅយ៉ាងណាខ្លះ ? ។

៣ - សួរបញ្ជាក់ទៅលោក ដោក ណារិន ក្នុងមូលហេតុយ៉ាងណាបានជាលោក ម្តងចេញសេចក្តីសំរេចប្រគល់ផ្ទះអោយលោក សូ រិន ម្តងទៀតចេញលិខិតបដិសេធសេចក្តីសំរេចនោះចោល ។

បាន ឃើញសាលដីការដ្ឋប្បវេណីលេខ ២២ ចុះថ្ងៃទី ២៨.៣.៩៦ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខលោកសូ រិន និង អ្នកការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខឈ្មោះដោកណារិន និង មាស សំអឿន ដែលមានខ្លឹមសារដូចតទៅ :-

១ - ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៣.៥.១៩៩៥ របស់ឈ្មោះ មាស សំអឿន និង ដោក ណារិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២ - តម្កល់ដីកាសំរេចតម្កល់រឿងទុកមិនចាត់ការលេខ ១១៩៨.ម.ប៩៥ ចុះថ្ងៃទី ០៨.៥.១៩៩៥ របស់ព្រះរាជអាជ្ញា អមតុលាការខេត្ត កំពង់ឆ្នាំង ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខលោក សូ រិន និង អ្នកការពារសិទ្ធិអោយដើមបណ្តឹងរដ្ឋប្បវេណី ដែលកំបាំងមុខគឺ ឈ្មោះ ដោក ណារិន និងមាន សំអឿន បើកផ្លូវសារទុក្ខក្នុងកំណត់ច្បាប់ ។ តាមបញ្ញត្តិមាត្រា ១០៩ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

បាន ឃើញសាលដីការបៀបលេខ ០៦ ចុះថ្ងៃទី ០៥.០២.៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១ - ទទួលបណ្តឹងឧទ្ធរណ៍ របស់នាង មាស សំអឿន និង បណ្តឹងឧទ្ធរណ៍របស់លោកម៉ែន គឿន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - សំរេចបញ្ចូលឃុំរឿងរដ្ឋប្បវេណីលេខ ៦២ ចុះថ្ងៃទី ១៧.១០.៩៧ របស់សាលាឧទ្ធរណ៍ ស្តីពីការប្តឹងសុំបដិសេធសេចក្តីសំរេចលេខ ៨១លសរគខ មុនត្រូវរឿងរដ្ឋប្បវេណីលេខ ២៥៦ ចុះថ្ងៃទី ២៨.០៥.៩៥ របស់សាលាឧទ្ធរណ៍ ស្តីពីការប្តឹងទាមទារកម្មសិទ្ធិផ្ទះកើតហេតុ ស្ថិតនៅខាងត្បូងជាប់ការិយាល័យដលផលខេត្ត បែរទៅមាត់ទន្លេ ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី ។

បាន ឃើញសាលដីការដ្ឋប្បវេណីលេខ ២៨ ចុះថ្ងៃទី ០៥.០២.៩៨ របស់សាលាឧទ្ធរណ៍ សំរេចចំពោះឈ្មោះ សូ រិន និង លោក ម៉ែន គឿន កំបាំងមុខឈ្មោះ មាស សំអឿន ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១ - ទទួលបណ្តឹងឧទ្ធរណ៍របស់នាង មាស សំអឿន ចុះថ្ងៃទី ៣០សីហា.១៩៩៥ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២ - ទទួលបណ្តឹងឧទ្ធរណ៍របស់លោក ម៉ែន គឿន នាយខុទ្ទកាល័យសាលាខេត្ត តំណាងអោយ

អភិបាលខេត្ត កំពង់ឆ្នាំង ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៧៩ ចុះថ្ងៃទី ១៨.៩.១៩៩៧ របស់តុលាការខេត្ត កំពង់ឆ្នាំង ដែលបានសំរេចបដិសេធសេចក្តីសំរេចលេខ ៨១សសរគខ របស់គណៈកម្មាធិការប្រជាជនខេត្តកំពង់ឆ្នាំង ចោលជាអសារបង់ ។

៤- តម្កល់សាលក្រមកំបាំងមុខលេខ ១៦ ចុះថ្ងៃទី០១.០៤.១៩៩៤ របស់តុលាការខេត្តកំពង់ឆ្នាំង ទុកជាបានការ ដែរដោយសេចក្តីវិនិច្ឆ័យនេះសេចក្តីប្រចប្តូកប្រចបល់គួរលុបចោល ហើយសរសេរអោយបានត្រឹមត្រូវឡើងវិញ ។

៥- សំរេចថា:-

ក- ប្រគល់ផ្ទះទាល់ផ្លែងជាន់លើ ក្រោម ដែលស្ថិតនៅខាងត្បូងជាប់ការិយាល័យដីធ្លីខេត្ត ដែលមុខទៅមាត់ទន្លេ អោយទៅលោក សូ រិន គ្រប់គ្រង និង កាន់កាប់ជាកម្មសិទ្ធិតាមសេចក្តីសំរេចលេខ ៨១សសរគខ ចុះថ្ងៃទី ២៥.០៧.១៩៨២ របស់គណៈកម្មាធិការប្រជាជនខេត្ត កំពង់ឆ្នាំង ។

ខ- បង្គាប់អោយលោក លាស់ ស៊ុំ និង នាង មាស សំអឿន សងប្រាក់ថ្លៃឈ្នួលផ្ទះក្នុងមួយខែ ៣០.០០០រៀល "បីម៉ឺនរៀល" គិតចាប់ពីខែ០៦ ឆ្នាំ ១៩៩២ រហូតដល់ថ្ងៃអនុវត្តសាលក្រម និង អោយសងជំងឺចិត្ត ចំនួន ២០លាន "ម្ភៃលានរៀល" ទៅលោក សូ រិន ។ ប្រាក់ជំងឺចិត្តទារលើសពីនេះបដិសេធចោល ។

គ- បង្គាប់អោយលោក លាស់ ស៊ុំ និង នាង មាស សំអឿន បង់ពន្ធសមាមាត្រ មួយភាគរយលើតំលៃផ្ទះ និង ប្រាក់ថ្លៃឈ្នួលផ្ទះ ព្រមទាំងប្រាក់ជំងឺចិត្តផងដែរ ។ ប្រាក់ពន្ធនេះ ៨០ភាគរយ ត្រូវបានជាប្រយោជន៍ថវិកាជាតិ និង ២០ភាគរយ ត្រូវបានជាប្រយោជន៍ក្រឡាបញ្ជីទូទាំងប្រទេស ។

៦- ទីបញ្ចូលប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ ដែលនាង មាស សំអឿន បានបង់រួចហើយ គឺ ពន្ធប្តឹង និង ពន្ធចុះបញ្ជីក្តី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់បញ្ជីប្រាក់ ៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០រៀល និង ចំណាយលើអាជ្ញាធរតុលាការ ៥០០០រៀល សរុប១៣.០០០រៀល ។

- ប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០រៀល ដែលលោក ម៉ែន គឿន តំណាងអោយសាលាខេត្តកំពង់ឆ្នាំង បានបង់រួចហើយ ត្រូវបង្វិលអោយលោក ម៉ែន គឿន វិញ ។

៧- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះឈ្មោះ សូ រិន និង លោក ម៉ែន គឿន កំបាំងមុខឈ្មោះ មាស សំអឿន បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

បាន ឃើញបណ្តឹងទាស់លេខ ១១ ចុះថ្ងៃទី ២៧.០៣.១៩៩៨ របស់អ្នកស្រី មាស សំអឿន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២៨ ចុះថ្ងៃទី ០៥.០២.៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បាន ឃើញសាលដីការដ្ឋប្បវេណីលេខ ២៥៨ ចុះថ្ងៃទី ២៨.០៩.៩៨ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខដើមចោទឈ្មោះ សូ រិន កំបាំងមុខដើមបណ្តឹងទាស់ឈ្មោះ មាស សំអឿន ជាលើកទីពីរ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :-

១- ទទួលបណ្តឹងទាស់លេខ ១១ ចុះថ្ងៃទី ២៧.០៣.១៩៩៨ របស់ឈ្មោះ មាស សំអឿន

ទុកជាត្រឹមត្រូវ តាមទំនងច្បាប់ តែបដិសេធចោលដោយទាល់នឹងគតិច្បាប់ ។

២ - តម្កល់សាលដីកាកំហុងមុខលេខ ២៨ ចុះថ្ងៃទី០៥.០២.១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមចោទ ឈ្មោះ សូ រិន កំហុងមុខដើមបណ្តឹងទាស់ឈ្មោះ មាស សំអឿន ជាលើកទីពីរ តែបាត់ទុកជាចំពោះមុខ ។

បើកល្បិចប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

បាន ឃើញបណ្តឹងសាទុក្ខលេខ ២៧៤ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់ អ្នកស្រី មាស សំអឿន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២៥៨ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បាន ឃើញសារណា ចុះថ្ងៃទី ២៣.៨.១៩៩៨ របស់អ្នកស្រី មាស សំអឿន

បាន ឃើញសារណាតប ចុះថ្ងៃទី ០៨.១០.១៩៩៨ របស់លោក សូ រិន

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការ ថា :-

លោក ដោក ណារិន ពិតជាបានធ្វើប្រធាន មន្ទីរបក្សខេត្ត និង ប្រធានខេត្ត ហើយ បានចេញសេចក្តីសំរេចជូនលោក សូ រិន ដោយមានសេចក្តីសំរេចលេខ ៨១ ចុះថ្ងៃទី២៥ ០៧.៩២ ជាភស្តុតាង ច្បាស់ ។

ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ មាស សំអឿន ជាចុងចម្លើយ និង ជាដើមបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបាន ឆ្លើយបញ្ជាក់ថា : ខ្លួន បានសុំពីលោក ដោក ណារិន តាំងពីឆ្នាំ ១៩៨១ គឺ នៅថ្ងៃទី ១៥.៨.៨១ ចុះដល់ថ្ងៃទី ២០.៩.៨១ លោក ម៉ែន ឡឿន ប្រធានមន្ទីរបក្សខេត្ត ជាអ្នកចាក់សោរអោយខ្លួន ចូលនៅតាមការបង្គាប់របស់លោក ដោក ណារិន ព្រមទាំងមាន រដ្ឋអំណាចភូមិ ឃុំ ជាអ្នកទទួលស្គាល់ផង មានពាក្យសុំផ្ទេរផ្ទះ និង មានសាក្សីដឹងឮទៀតផង ។

នៅថ្ងៃទី ១២.០៧.៩៣ លោក ដោក ណារិន បានចេញលិខិតបដិសេធសេចក្តីសំរេច ចោលទាំងស្រុងតទៅ ២ដង ។ ចំពោះលោក សូ រិន លោក ដោក ណារិន បានដោះស្រាយ ផ្ទះ ២ល្វែងជូនលោក សូ រិន រួចទៅហើយ ថែមទាំងបានជួយសំរួលដាក់ឈ្មោះកូនគាត់ទៀតផង ។ ហើយលោក សូ រិន មិនដែលបានចូលស្នាក់នៅក្នុងផ្ទះនេះទេ ហើយការចូលមករស់នៅក្នុងផ្ទះនេះ ខ្លួន បានចំណាយប្រាក់យ៉ាងច្រើន ដើម្បីជួសជុលផ្ទះនោះដោយមានលោកប្រធានភូមិ ផ្សារឆ្នាំង ជាអ្នកដឹងឮផង ។ នៅឆ្នាំ ១៩៩២ លោក សូ រិន និង លោក ម៉ែន ឡឿន បានឃុបឃិតគ្នា លួចធ្វើសេចក្តីសំរេចដោយអាងអំណាចរបស់គាត់ លុះបានសេចក្តីសំរេច គាត់ ក៏បញ្ជាទៅលោក ម៉ែន ឡឿន អោយទៅបង្ខិតបង្ខំខ្លួន ធ្វើកិច្ចសន្យាដូរផ្ទះពីលោក សូ រិន តែខ្លួនមិនព្រម ។

បានស្តាប់ចម្លើយរបស់ឈ្មោះ សូ រិន ជាដើមចោទ និង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា ៖ ចំពោះចំលើយទាំងប៉ុន្មានរបស់អ្នកស្រី មិនមែនជាការពិតទេ ខ្លួនពឹងផ្អែកទៅលើតុលាការធ្វើការពិចារណា ។ ព្រោះនៅពេលកងទ័ពវៀតណាម ដកចេញពីកម្ពុជា អង្គភាពនោះ៨៥០២ របស់វៀតណាម ឈរជើងនៅខេត្ត កំពង់ឆ្នាំង បានប្រគល់ផ្ទះល្វែង និង ដី ជូនមកគណៈកម្មាធិការបក្សខេត្ត កំពង់ឆ្នាំងគ្រប់គ្រង និង ចាត់ចែង ប្រើប្រាស់តាមសិទ្ធិរបស់ខ្លួន ។ តែគណៈកម្មាធិការបក្សខេត្ត ក៏បានប្រគល់អោយមន្ទីរគណៈបក្សខេត្ត គ្រប់គ្រងដោយឃើញថា ផ្ទះទាំងអស់មានសភាពទំនេរ ហើយខ្លួន ក៏មិនទាន់បានទទួលផ្ទះណាមួយពីគណៈកម្មាធិការបក្សខេត្ត សំរាប់ប្រើប្រាស់ផ្ទាល់ខ្លួន ខ្លួនបានរួមជាមួយលោក ម៉ែន ធឿន ,លោក ស៊ឹម សារុន បានធ្វើពាក្យស្នើសុំផ្ទះល្វែងម្នាក់ ពីលោក ដៅក ណារិន ។ ហើយផ្ទះល្វែងដែលជាផ្ទះទំនាស់នោះ គឺខ្លួន បានស្នើសុំតាមរយៈលោក ម៉ែន ធឿន ទេ ។ ហើយខ្លួន គ្មានផ្ទះល្វែងណាដែលក្រៅពីផ្ទះទំនាស់នេះទេ ។ ដោយមានស្រឡាញ់រាប់អានគ្នារវាងខ្លួន និង ប្តីអ្នកស្រីមាស សំអឿន ទើបខ្លួន ហ៊ានអោយជួលដោយមិនបានធ្វើកិច្ចសន្យាទេ ។សុំអោយតុលាការពិនិត្យពិចារណាទៅលើឯកសារទាំងអស់ដែលមានស្រាប់ ហើយការជជែកគ្នាចុះឡើង ក៏បណ្តាលអោយមានទំនាស់កាន់តែខ្លាំងដែរ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៧៤ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៨របស់អ្នកស្រី មាស សំអឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបាន តាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការដែលអ្នកស្រី មាស សំអឿន លើកឡើងក្នុងសារណារបស់អ្នកស្រីថា ផ្ទះទំនាស់នេះត្រូវបានលោក ដៅក ណារិន អតីតប្រធានគណៈកម្មាធិការប្រជាជនខេត្តកំពង់ឆ្នាំង សំរេចប្រគល់អោយអ្នកស្រីនោះ ពុំមានភស្តុតាងជាលាយលក្ខណ៍អក្សរណាមួយអាចយកជាការបានឡើយ ។ ផ្ទុយទៅវិញមានតែសេចក្តីសំរេចជាលាយលក្ខណ៍អក្សរប្រគល់ផ្ទះទំនាស់នេះជូនទៅលោក សូ រិន ។

- យល់ឃើញថា សេចក្តីសំរេចលេខ ៨១ សសរ.គខ ចុះថ្ងៃទី ២៥.០១.៩២ ដែលអ្នកស្រីមាស សំអឿន បានលើកឡើងក្នុងសារណារបស់អ្នកស្រីថា ត្រូវបានលោកដៅក ណារិន ដែលជាអ្នកចុះហត្ថលេខា បានធ្វើលិខិតបដិសេធជាច្រើនដងហើយ ពុំអាចយកជាការបានទេនោះ ជាការភន្តច្រឡំ ព្រោះថា លិខិតបដិសេធរបស់លោក ដៅក ណារិន ធ្វើឡើងពុំមែនក្នុងនាមលោក ជានីតិបុគ្គលដែលលោកកំពុងស្ថិតនៅជាមន្ត្រីមានសមត្ថកិច្ចដែលអាចនាំអោយមោឃភាពសេចក្តីសំរេចខាងលើនេះបាន តាមមាត្រា ៨ និង ១១ នៃ

---៩--

ក្រិត្យ-ច្បាប់លេខ ០៧ក្រ.ច ចុះថ្ងៃទី ១៣.៧.៨២ ស្តីពីលមត្ថកិច្ច និង នីតិវិធីនៃការធ្វើច្បាប់ និង បទបញ្ញាបាន ទេ ។

- យល់ឃើញថា ការដែលអ្នកស្រី ទាវ សំអឿន លើកឡើងក្នុងសារណារបស់អ្នកស្រីថា អ្នកស្រី ពុំដែលបានចុះហត្ថលេខា ម្តងណាជាមួយលោក សូ រិន ដើម្បីជួលផ្ទះពីលោកម្តងណាទេនោះជាការពុំត្រឹមត្រូវទេពីព្រោះថា អ្នកស្រីអាចឡើងទៅនៅលើផ្ទះនេះបានក៏ដោយសារលោកម៉ែន គៀន ហើយលោក ម៉ែន គៀន ដែលជាអ្នកគ្រប់គ្រងផ្ទះទាំងនេះពីមុនមកក៏បានទទួលស្គាល់នូវការជួលនេះដែរ ប៉ុន្តែគ្រាន់តែពុំបានធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ ។

- យល់ឃើញថា សាលដីការដ្ឋបូរេវណីលេខ ២៥៨ ចុះថ្ងៃទី ២៨.៥.៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

ដោយហេតុនេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១ - ទទួលបណ្តឹងសាទុក្ខលេខ ២៧៤ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៨ របស់អ្នកស្រី ទាវ សំអឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីការដ្ឋបូរេវណីលេខ ២៥៨ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - ទីបនូវប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០រៀល ដែលលោក សូ រិន បានបង់រួចហើយគឺ :-

- ពន្ធចុះបញ្ជីក្តី និង ពន្ធប្តឹង ចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ដាក់ថ្លៃក្រឡាបញ្ជីការពិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីការកោះ ចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយត្រូវអោយអ្នកស្រី ទាវ សំអឿន សងប្រាក់ ចំនួន ១៩.០០០រៀល នេះទៅលោក សូ រិន វិញ ។

បង្គាប់អោយអ្នកស្រី ទាវ សំអឿន បង់ពន្ធលទាមាត្រ តាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ។